# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤២ សសរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការកែសម្រួលសមាសភាព និងភារកិច្ចគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្ដីសម្រេចលេខ ៥៨ ស.ស.រ. ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវបណ្ឌិត | **ពេជ ចន្ទមុន្នី** | ប្រធាន |
| ២. ឯកឧត្តម | **សុខ ពុទ្ធិវុធ** | អនុប្រធាន |
| ៣. ឯកឧត្តម | **ស៊ាន បូរ៉ាត** | អនុប្រធាន |
| ៤. លោក | **ជា ពិសី** | សមាជិក |
| ៥. ឯកឧត្តម | **ជួន ជីវិន** | សមាជិក |
| ៦. លោក | **អ៊ុក ច័ន្ទវាសនា** | សមាជិក |
| ៧. លោក | **ពេញ ធារម្យ** | សមាជិក |
| ៨. ឯកឧត្តម | **ម៉ុក ច័ន្ទសុធា** | សមាជិក |
| ៩. ឯកឧត្តម | **ឡាវ វ៉ាន់** | សមាជិក |
| ១០. ឯកឧត្តម | **ម៉ែ ស៊ីថន** | សមាជិក |
| ១១. លោក | **កែវ គឹមឃន** | សមាជិក |



https://www.moj.gov.kh/kh/law-regular

| | | | |
|---|---|---|---|
| ១២. ឧកញ៉ា | **លឹម** | **សុជាតិ** | សមាជិក |
| ១៣. លោកស្រី | **ម៉ី** | **តាវី** | សមាជិកា។ |

**ប្រការ២.-**

ត្រូវបានកែសម្រួលភារកិច្ចគណៈកម្មាធិការ អាហារូបករណ៍សិស្ស-និស្សិតក្រីក្រ ដូចតទៅ៖

- អំពាវនាវគ្រឹះស្ថានសិក្សានានា នៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីរកអាហារូបករណ៍
- គ្រប់គ្រង និងបែងចែកដល់សិស្ស-និស្សិតក្រីក្រ នូវអាហារូបករណ៍ ដែលគ្រឹះស្ថានសិក្សានានាផ្តល់ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត តាមរយៈ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត**
- ធ្វើការពិនិត្យបណ្តាសិស្ស-និស្សិតអាហារូបករណ៍ដែលគណៈកម្មាធិការបានផ្តល់ជូន
- ធ្វើរបាយការណ៍ជូន សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃ ព្រហស្បតិ៍ ៦ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular